គ្លីនិក៉ាក់

Description : អង្គការ៉ាក់ទទួលស្គាល់អំពីភាពចាំបាច់ក្នុងការជួយសម្រាលបន្ទុករបស់គ្រឹះស្ថានផ្តល់សេវាសុខភាពរដ្ឋដោយអង្គការបានផ្ទេរការផ្តល់សេវាសុខភាពរបស់ខ្លួន---ទៅដល់ក្រុមប្រជាជននៅទីក្រុងដែលមានលទ្ធភាពបង់ថ្លៃ ក៏ដូចជាប្រជាជនក្រីក្រនិងក្រុមងាយរងគ្រោះដែលមានការលំបាកក្នុងការមកទទួលសេវាសុខាភិបាលសាធារណៈ ដូចជា៖ កម្មកររោងចក្រ នឹងកម្មករចំណាកស្រុក ក្រុមស្ត្រីធ្វើការនៅសេវាកម្សាន្ត ក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកបំឡែងភេទ និងក្រុមយុវវ័យ ដោយសារក្រុមទាំងនេះ មកទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈមានកំរិតនៅឡើយ ហើយពួកគេងាយនឹងស្ថិតនៅក្រៅការគ្របដណ្តប់របស់ប្រព័ន្ធសុខាភិបាលនាពេលបច្ចុប្បន្ន។

គោលបំណង

តាមរយៈគ្លីនិកទាំងអស់របស់ខ្លួន អង្គការ៉ាក់នឹងបង្កើនការទទួលបានសេវាសុខភាពផ្លូវភេទ និងបន្តពូជ សេវាពន្យារកំណើត និងសេវាទាក់ទងនឹងជំងឺកាមរោគនិងជំងឺអេដស៍ និងការទទួលបានពត៌មានអប់រំសុខភាព ក្នុងចំណោមប្រជាជនក្រីក្រ ក្រុមដែលមិនទាន់ទទួលបានទទួលសេវាសុខភាពគ្រប់គ្រាន់ ក្រុមយុវវ័យ ក្រុមងាយរងគ្រោះផ្សេងទៀត និងប្រជាជនទូទៅ។

សកម្មភាព

អង្គការ៉ាក់បន្តផ្តល់កញ្ចប់សេវាសុខភាពគ្រប់ជ្រុងជ្រោយ តាមរយៈគ្លីនិកទាំង ១៥ របស់ខ្លួន។ គ្លីនិក៉ាក់មានលក្ខណៈខុសប្លែក ពីអ្នកផ្តល់សេវាដទៃទៀត ដោយសារបែបបទរបស់យើងក្នុងការយកចិត្តទុកដាក់ និងការប្រាស្រ័យជាមួយអតិថិជន។ រាល់សកម្មភាពផ្តល់សេវារបស់គ្លីនិក គឺផ្តោតទៅលើការពេញចិត្តរបស់អតិថិជន ភាពរួសរាយរាក់ទាក់របស់បុគ្គលិកផ្តល់សេវា បរិយាកាសអំណោយផល និងសេចក្តីណែនាំច្បាស់លាស់សម្រាប់បុគ្គលិក ។ គុណភាពនៃការថែទាំ ត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ ជាមួយនឹងប្រព័ន្ធច្បាស់លាស់សម្រាប់ផ្តល់ពិន្ទុ និងផែនការតាមដានច្បាស់លាស់ដើម្បីកែលម្អគុណភាព ។

ភាពគ្រប់ជ្រុងជ្រោយនៃសេវាសុខភាពផ្លូវភេទ និងបន្តពូជដែលផ្តល់ដោយគ្លីនិក៉ាក់ គឺជាផ្នែកមួយនៃការខិតខំប្រឹងប្រែងរបស់យើង ដើម្បីឲ្យគ្លីនិកក្លាយជាកន្លែងច្រកចេញចូលតែមួយក្នុងការផ្តល់សេវា ដោយរួមបញ្ចូលទាំង ទីតាំងងាយស្រួលរក ម៉ោងបម្រើការងារជាក់លាក់សម្រាប់ក្រុមចំនុច គោលការណ៍កំណត់តម្លៃសេវាសម្រាប់ជនក្រីក្រ នឹងក្រុមភាគតិចដែលពិបាកក្នុងការទទួលសេវា និងការណែនាំច្បាស់លាស់ទៅដល់អតិថិជនពេលបញ្ជូនចេញក្រៅ។ តាមរយៈការប្តេជ្ញាចិត្តក្នុងការផ្តល់សេវាសុខភាពប្រកបដោយគុណភាព អង្គការ៉ាក់បានទទួលវិញ្ញាបនប័ត្រទទួលស្គាល់គុណភាពជាផ្លូវការ ពីសហព័ន្ធផែនការគ្រួសារអន្តរជាតិ (IPPF) ក្នុងឆ្នាំ ២០១៣។